ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2015, 15:10
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរិវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

---

# សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

---

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, Phnom Penh, P.O. Box 71, Phnom Penh Tel:+855(0)23 219814 Fax: +855(0)23 219841
Web: www.eccc.gov.kh

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Nicholas KOUMJIAN

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

សុន អរុណ

Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ "អង្គជំនុំជម្រះ" និង "អ.វ.ត.ក") បានទទួលសំណើមួយដែលត្រូវបានដាក់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ដោយមេធាវីការពារក្តីសម្រាប់ជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៤ ("មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤" និង "ជនសង្ស័យក្នុងសំណុំរឿង ០០៤") ស្នើសុំដាក់សារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី* *(amicus curiae)* ស្តីពីភាពអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មទម្រង់ទី៣") នៅ អ.វ.ត.ក[1] រួមទាំងសំណើមួយស្រដៀងគ្នានេះដែលត្រូវបានដាក់នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ដោយមេធាវីការពារក្តីសម្រាប់ជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៣ ("មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣" និង "ជនសង្ស័យក្នុងសំណុំរឿង ០០៣") ដើម្បីធ្វើអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឬជាជម្រើសម្យ៉ាងទៀត សុំដាក់សារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី* ទៅលើប្រធានបទដដែលនោះ[2]។

## **ក. សាវតារ**

២. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ("សាលក្រមសាលាដំបូង")[3] ដោយបានសម្រេចថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមមានការសម្លាប់រង្គាល (រួមទាំងការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំង ការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តី

---

[1] សំណើសុំដាក់សារណារបស់សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី ស្តីពីសហឧក្រិដ្ឋកម្មរួម ឯកសារ F19 ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ("សំណើពីសំណុំរឿង ០០៤")។

[2] សំណើរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ សុំធ្វើអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ក្នុងគោលបំណងលើកឡើងអំពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មទម្រង់ទី៣ នៅ អ.វ.ត.ក ឬ ម្យ៉ាងទៀត ស្នើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មទម្រង់ទី៣ ឯកសារ F20 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ("សំណើពីសំណុំរឿង ០០៣")។

[3] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

01085738



ផ្ទៃផ្ទះរបស់មនុស្សជាតិ) ហើយបានផ្តន្ទាទោសពួកគេឲ្យជាប់ពន្ធនាគារអស់មួយជីវិត[4]។

៣. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញា បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង ("សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ")[5] បន្ទាប់មកពួកគេបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("បណ្តឹងសាទុក្ខ")[6]។ បណ្តឹងសាទុក្ខបានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសលើអង្គច្បាប់ដោយបានសម្រេចថា សហឧក្រិដ្ឋកម្មទម្រង់ទី ៣ មិនមែនជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ[7]។ នៅក្នុងការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេ សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួន"ពុំមានបំណងប្តឹងសាទុក្ខលើផ្នែកសម្រេចសេចក្តីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ឬលើការរកឃើញផ្នែកអង្គហេតុ និងអង្គច្បាប់" នៅក្នុងសាលក្រមនោះឡើយ[8]។

## ខ. <u>សារណា</u>

### ១. សំណើរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤

៤. មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ ជំទាស់ថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបានតាមទំរង់ទេ និងបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រកាសថា មិនអាច

---

[4] សាលក្រមសាលាដំបូង ទំព័រ ៦២២។

[5] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[6] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ F11 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ សាលក្រមសាលាដំបូងក៏ត្រូវបានប្តឹងសាទុក្ខដោយ នួន ជា និង ខៀវ សំផនដែរ។ *សូមមើល* បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ F16 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។ *[Corrigé 1] Mémoire d'appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01* ឯកសារ F17 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (សំណៅដែលបានកែប្រែត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១* ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[7] សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ កថាខណ្ឌ ២ ដល់ ៣។

[8] សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ កថាខណ្ឌ ១០។

ទទួលយកបានទេ ឬជាជម្រើសម្យ៉ាងទៀត អនុញ្ញាតឲ្យដាក់សារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តនៃសហឧក្រិដ្ឋកម្មទម្រង់ទី ៣ នៅ អ.វ.ត.ក[9]។ មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ លើកឡើងថា បណ្តឹងសាទុក្ខនោះ ស្នើសុំឱ្យប្រកាសថាទម្រង់នៃការទទួលខុសត្រូវនេះអាចអនុវត្តបាននៅ អ.វ.ត.ក ហេតុដូច្នេះហើយ ក៏អាចអនុវត្តបានចំពោះជនសង្ស័យដោយទម្រង់នៃការទទួលខុសត្រូវនេះ ពុំមាននៅក្នុងច្បាប់ទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[10]។ មេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ លើកឡើងថា ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះ គប្បីទទួលយកសារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី*ផងដែរ ដើម្បីឱ្យជនសង្ស័យ អាចមានមធ្យោបាយការពារខ្លួនបានពេញលេញ ទៅលើបញ្ហាណាមួយដែលធ្វើឲ្យប៉ះពាល់ជាសក្តានុពល[11]។

## ២. សំណើសុំរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣

៥. មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ បានអះអាងថា ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចស្តាប់សវនាការលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទោះបីបណ្តឹងសាទុក្ខនោះត្រូវបានមើលឃើញថា "មិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែត"ក៏ដោយ[12] អង្គជំនុំជម្រះតុលាការកំពូលត្រូវអនុញ្ញាតឲ្យមេធាវីការពារក្តីក្នុងសំណុំរឿង ០០៤ ធ្វើបទអន្តរាគមន៍ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ[13] ឬជាជម្រើសម្យ៉ាងទៀត អនុញ្ញាតឲ្យដាក់សារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មទម្រង់ទី ៣ នៅ អ.វ.ត.ក[14]។ មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ លើកឡើងថា ការអន្តរាគមន៍របស់ខ្លួនក្នុងនាមជាភាគីមានផលប្រយោជន៍ក្នុងសំណុំរឿង ០០២ ជាការត្រឹមត្រូវ ដោយសារលទ្ធផលនៃបញ្ហានេះ នឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើជនសង្ស័យក្នុងសំណុំរឿង ០០៣ ដែលត្រូវបានចោទប្រកាន់ថា បាន

---

[9] សំណើពីសំណុំរឿង ០០៤ កថាខណ្ឌ ៤ ដល់ ២០, ទំព័រ ១០។

[10] សំណើពីសំណុំរឿង ០០៤ ទំព័រ ១, កថាខណ្ឌ ១ ដល់ ៣ និង ២០។

[11] សំណើពីសំណុំរឿង ០០៤ កថាខណ្ឌ ២ ដល់ ៣ និង ២០។

[12] សំណើពីសំណុំរឿង ០០៣ កថាខណ្ឌ ១ និង ៥។ ទឡ្ហីករណ៍នានាស្តីពីភាពមិនអាចទទួលយកបាននៃបណ្តឹងសាទុក្ខមាននៅក្នុងជើងទំព័រ ៤។

[13] សំណើពីសំណុំរឿង ០០៣ ទំព័រ ១, ៨, កថាខណ្ឌ ១ ដល់ ៨។

[14] សំណើពីសំណុំរឿង ០០៣ ទំព័រ ១, ៨, កថាខណ្ឌ ៩ ដល់ ១៧។

ប្រព្រឹត្តឧក្រិដ្ឋកម្មនានា តាមរយៈសហឧក្រិដ្ឋកម្មទម្រង់ទី ៣[15] ហើយជំទាស់ថា ការបដិសេធមិនអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០២ ដោយផ្អែកលើមូលដ្ឋានថា សហឧក្រិដ្ឋកម្មទម្រង់ទី ៣ អាចនឹងត្រូវបានជំទាស់នៅក្នុងសំណុំរឿង ០០៣ នាពេលក្រោយទៀតនោះ នឹងពុំបានការពារពេញលេញដល់ផលប្រយោជន៍របស់មេធាវីការពារក្ដីក្នុងសំណុំរឿង ០០៣ ទេ និងពុំមែនជាប្រយោជន៍នៃសេដ្ឋកិច្ចតុលាការដែរ[16]។

៦. ជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្ដីក្នុងសំណុំរឿង ០០៣ ស្នើសុំដើរតួនាទីជា *អ្នកដែលមិនមែនភាគីនៃរឿងក្ដី* អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង[17]។ មេធាវីការពារក្ដីអះអាងថា គ្មានភាគីណាមួយ នឹងទទួលរងព្យសនកម្មដោយសារសារណានេះឡើយ ហើយថា សារណារបស់*អ្នកដែលមិនមែនភាគីនៃរឿងក្ដី* មិនមានបំណងជួយមេធាវីការពារក្ដី នួន ជា ឬ ខៀវ សំផន ទេ គ្រាន់តែជាដំណោះស្រាយបញ្ហាផ្លូវច្បាប់ដែលនឹងប៉ះពាល់ដល់សំណុំរឿង ០០៣ ប៉ុណ្ណោះ[18]។ ក្នុងករណីនេះ មេធាវីការពារក្ដីក្នុងសំណុំរឿង ០០៣ លើកឡើងបន្ថែមថា យុត្តិសាស្ត្រអន្តរជាតិបង្ហាញថា *អ្នកដែលមិនមែនភាគីនៃរឿងក្ដី* អាចបញ្ចូលដោយស្របច្បាប់នូវភាគីនានាដែលមានផលប្រយោជន៍ចំពោះបញ្ហាដែលស្ថិតក្រោមការវិនិច្ឆ័យរឿងក្ដី[19]។

## គ. __ការពិភាក្សា__

៧. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលធ្វើការបញ្ជាក់ថា ទឡ្ហីករណ៍នានាដែលពាក់ព័ន្ធនឹងភាពអាចទទួលយកបាន ឬខ្លឹមសារនៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នឹងពុំត្រូវបានដោះស្រាយនៅក្នុងសេចក្ដីសម្រេចបច្ចុប្បន្ននេះទេ ហើយការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើសំណើពីសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ ដើម្បីធ្វើអន្តរាគមន៍ ឬ ដើរតួនាទីជា*អ្នកដែលមិនមែនភាគីនៃរឿងក្ដី* (ជាជម្រើសនៃការសន្និដ្ឋានថា បណ្ដឹងសាទុក្ខមិនអាចទទួលយកបាន) មិនគួរត្រូវបានបកស្រាយថា ជាការចង្អុលបង្ហាញនូវភាពអាចទទួលយកបាន*តាមសេចក្ដីបញ្ជាក់ដំបូង*នៃបណ្ដឹងសាទុក្ខឡើយ។

---

[15] សំណើពីសំណុំរឿង ០០៣ ទំព័រ ១ កថាខណ្ឌ ១, ៣ ដល់ ៤, ៦ ដល់ ៧។

[16] សំណើពីសំណុំរឿង ០០៣ កថាខណ្ឌ ២ ដល់ ៥។

[17] សំណើពីសំណុំរឿង ០០៣ កថាខណ្ឌ ៩។

[18] សំណើពីសំណុំរឿង ០០៣ កថាខណ្ឌ ១០ ដល់ ១១។

[19] សំណើពីសំណុំរឿង ០០៣ កថាខណ្ឌ ១២ ដល់ ១៧។

៨. វិធាន ៣៣ នៃវិធានផ្ទៃក្នុង[20] ចែងថា "នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថា ចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចអញ្ជើញ ឬផ្តល់ឱកាសឲ្យអង្គការ ឬបុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បាន"។ ផ្អែកលើវិធានដែលមានសេចក្តីបញ្ញាក់ប្រហាក់ប្រហែលគ្នា[21] យុត្តាធិការរបស់តុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានា បានបង្ហាញពីភាពទូលំទូលាយនៃបុគ្គល ឬស្ថាប័ននានាជាច្រើនដែលអាចដើរតួនាទីជា*អ្នកដែលមិនមែនភាគីនៃរឿងក្តី* និងលក្ខណៈវិនិច្ឆ័យកំណត់ជាទូទៅនូវខ្លឹមសារនៃសារណារបស់ពួកគេ[22]។ ទោះជាយ៉ាងណាក៏ដោយ តួនាទីចម្បងរបស់*អ្នកដែលមិនមែនភាគីនៃរឿងក្តី*នៅក្នុងបញ្ហាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺជាការជួយដល់តុលាការនៅក្នុងការសម្រេចលើរឿងក្តីណាមួយ ជាពិសេសលើបញ្ហាច្បាប់ដែលពាក់ព័ន្ធទៅនឹង

---

[20] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី ៩ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង")។

[21] *សូមមើល* វិធាន ១០៣(១) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ: "នៅដំណាក់កាលជំនុំជម្រះ អង្គជនុំជម្រះអាច ប្រសិនបើពិចារណាឃើញថាចាំបាច់សម្រាប់ការវិនិច្ឆ័យលើរឿងក្តីឱ្យបានត្រឹមត្រូវ អញ្ជើញ ឬផ្តល់ឱកាសឱ្យរដ្ឋ អង្គការ ឬបុគ្គលណាមួយដើម្បីដាក់ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នូវការអង្កេតណាមួយលើបញ្ហា ដែលអង្គជំនុំជម្រះយល់ថាសមស្រប"។ វិធាន ៧៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTY: "អង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសដល់រដ្ឋ, អង្គការ ឬបុគ្គល ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់សម្រាប់ការវិនិច្ឆ័យសមស្រប ដើម្បីចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងធ្វើសេចក្តីសន្និដ្ឋានលើបញ្ហាណាមួយដែលបានកំណត់យ៉ាងជាក់លាក់ដោយអង្គជំនុំជម្រះ"។ វិធាន ៧៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR ចែងបទប្បញ្ញត្តិដូចគ្នា។

[22] *សូមមើល ក្នុងចំណោមនោះ* តុលាការព្រហ្មទណ្ឌអន្តរជាតិ *ស្ថានភាពនៅសាធារណរដ្ឋកេនយ៉ា* សំណុំរឿងលេខ ICC-01/09 សេចក្តីសម្រេចស្តីពីពាក្យសុំដាក់សេចក្តីសង្កេតរបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើអ្នកដែលមិនមែនភាគីក្នុង*រឿងក្តី Ruto*") កថាខណ្ឌ ៦ (ភាសាអង់គ្លេស)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gbagbo* សំណុំរឿងលេខ ICC-02/11-01/12 សេចក្តីសម្រេចលើ "សំណើសុំការអនុញ្ញាតដាក់សេចក្តីសង្កេតរបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី អនុលោមតាមវិធាន ១០៣(១) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង" អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣ ("សេចក្តីសម្រេចលើអ្នកដែលមិនមែនភាគីក្នុង*រឿងក្តី Gbagbo*") កថាខណ្ឌ ៩ (ភាសាអង់គ្លេស)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-AR98*bis*.1 សេចក្តីសម្រេចស្តីពីពាក្យសុំការអនុញ្ញាតឲ្យដាក់សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ (សេចក្តីសម្រេចលើអ្នកដែលមិនមែនភាគីក្នុង*រឿងក្តី Karadžić*") ទំព័រ ២ (ភាសាអង់គ្លេស)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bagosora* សំណុំរឿងលេខ ICTR-96-7-T សេចក្តីសម្រេចស្តីពីពាក្យសុំរបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រប៊ែលហ្ស៊ិក ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៩៨ ទំព័រ ២ ។

កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន[23] ដែលមានខ្លឹមសារបន្ថែមឲ្យបានគ្រប់គ្រាន់ទៅលើទឡ្ហីករណ៍នានាដែលបានទទួលពីភាគីនៃរឿងក្ដីរួចហើយ[24]។

៩. ដោយកត់សម្គាល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិ បង្ហាញនូវភាពមិនស៊ីសង្វាក់គ្នាមួយចំនួនទាក់ទិននឹងបញ្ហាថាតើ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* ចាំបាច់ត្រូវមានភាពអនាគតិ ដែរ ឬយ៉ាងណា[25] និងលក្ខខណ្ឌតម្រូវនៃភាពអនាគតិ"យ៉ាងដាច់ខាត"នេះ ជាក់ស្ដែង ពុំអាចកើតមាន ទើបអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សម្រាប់ការបំពេញមុខនាទីរបស់ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* ក្នុងការជួយដល់តុលាការ គឺនៅតែចាំបាច់ត្រង់ថា បំណងរបស់បុគ្គល ឬស្ថាប័នក្នុងការដាក់សារណារបស់ខ្លួន គឺដើម្បីមូលហេតុផលប្រយោជន៍អរូបីលើបញ្ហាជាក់លាក់ណាមួយ ជាជាងក្នុងន័យ ជំរុញ ឬបង្កើតឱ្យមាននូវលទ្ធផលជាក់លាក់ណាមួយទាក់ទងនឹងករណីព្រហ្មទណ្ឌ។ ដោយសារតែហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពីលើកមុនថា *អ្នកមិនមែនជាភាគីនៃរឿងក្ដី*គួរតែជាអ្នកដែលពុំមានការជាប់ពាក់ព័ន្ធនឹងតុលាការ ឬការិយាល័យណាមួយរបស់តុលាការឡើយ[26]។ បន្ថែមលើនេះទៀត សារណារបស់បុគ្គល ឬស្ថាប័ននានា ដែលមានផលប្រយោជន៍អរូបីនៅក្នុងបញ្ហាដែលត្រូវយកមកវិនិច្ឆ័យនោះ អាចត្រូវបានទទួលយកដោយស្របច្បាប់ ដរាបណាសារណាទាំងនោះ ត្រូវបានចាត់ទុកថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវទៅលើរឿងក្ដី។ សម្រាប់ហេតុផលដែលនឹងត្រូវរៀបរាប់ពេញលេញថែមទៀតនៅខាងក្រោមនេះ អង្គជំនុំជម្រះតុលាការ

---

[23] សេចក្ដីសម្រេចលើអ្នកដែលមិនមែនភាគីក្នុង *រឿងក្ដី Karadžić* ទំព័រ ២ ។

[24] សេចក្ដីសម្រេចលើអ្នកដែលមិនមែនភាគីក្នុង *រឿងក្ដី Gbagbo* កថាខណ្ឌ ៩ ។

[25] អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ថា "ហេតុផលដ៏សំខាន់ដែលជាមូលដ្ឋាននៃសារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* គឺថា មានការជួយទៅដល់អង្គជំនុំជម្រះនៅក្នុងការសម្រេចអំពីរឿងក្ដីពីសំណាក់អ្នកអន្តរាគមន៍ឯករាជ្យ និងមិនលម្អៀង ដែលពុំមានឋានៈផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ"។ *សូមមើល*សេចក្ដីសម្រេចស្ដីពី *អ្នកមិនមែនជាភាគីនៃរឿងក្ដី Ruto* កថាខណ្ឌ ៦។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា បានកត់សម្គាល់ថា "និយមន័យទូទៅនៃ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* មិនទាមទារឲ្យមានភាពមិនលម្អៀងរបស់ភាគីដាក់សារណានោះទេ" ហើយថា "សារណាបែបនេះត្រូវបានដាក់ដោយភាគីមួយ ដែលមិនមែនជាផ្នែកនៃបណ្ដឹង ប៉ុន្តែជាអ្នកដែលមានផលប្រយោជន៍ខ្លាំង ឬមានទស្សនៈលើរឿងក្ដីនៅចំពោះមុខតុលាការ"។ *សូមមើល រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង Bagosora សំណុំរឿងលេខ* ICTR-96-7-T សេចក្ដីសម្រេចលើសំណើរបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ដោយរដ្ឋាភិបាលប្រទេសប៊ែលហ្សិក ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៨ ទំព័រ ២។ (បន្ថែមអក្សរផ្ដេក)។

[26] សេចក្ដីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្ដី សុំដាក់សារណារបស់ *អ្នកដែលមិនមែនជាតួភាគីនៃរឿងក្ដី* មកកាន់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ F7/2 ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ៩។

កំពូលយល់ឃើញថា ដោយបន្ថែមទៅលើការពិតដែលថា មេធាវីការពារក្តីសំណុំរឿង ០០៣ និង ០០៤ មានផលប្រយោជន៍យ៉ាងច្បាស់នៅក្នុងបញ្ហាបច្ចុប្បន្ន និងលទ្ធផលនៃបញ្ហានេះ មេធាវីការពារក្តី ពុំអាចផ្តល់នូវសារណាបន្ថែមណាមួយ ក្រៅតែពីសារណាទាំងឡាយដែលបានដាក់រួចមកហើយ ក្នុងគោលបំណងដើម្បីបំភ្លឺបន្ថែមទៀតទៅលើបញ្ហានេះទេ។ ដូច្នេះ អង្គជនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានភាពចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវទៅលើរឿងក្តីនេះ ក្នុងការអនុញ្ញាតតាមសំណើសុំដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី*ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះ បដិសេធសំណើសុំនៃសំណុំរឿង ០០៣ និង ០០៤ ទាក់ទិននឹងបញ្ហានេះ។

១០. ផ្ទុយទៅនឹងតួនាទីរបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* ដែលបានកំណត់ជាទូទៅនៅចំពោះមុខសាលាក្តី និងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា និងនៅចំពោះមុខ អ.វ.ត.ក គឺថា ពុំមានបទប្បញ្ញត្តិជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬក្នុងវិធានស្តីពីនីតិវិធី និងភស្តុតាងនៃសាលាក្តី និងតុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងភាពអាចទទួលយកបានរបស់អ្នកធ្វើអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនិតិវិធីឡើយ។ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្តីនានា ផ្តល់នូវការយល់ឃើញតិចតួចអំពីលក្ខណៈវិនិច្ឆ័យក្នុងការទទួលយកអន្តរាគមន៍ពីតតិយជន។ នៅក្នុងការគាំទ្រសំណើសុំអន្តរាគមន៍របស់ខ្លួន មេធាវីការពារក្តីសំណុំរឿង ០០៣ លើកឡើងអំពីរឿងក្តី *Kallon* និង *Kamara* នៅចំពោះមុខតុលាការពិសេសសម្រាប់សេរ៉ាឡេអូន (“SCSL”) ដោយក្នុងរឿងក្តីនោះ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីសុពលភាពនៃការអនុគ្រោះទោសដល់ Lomé Accord នឹងប៉ះពាល់ដល់ជនជាប់ចោទពីរនាក់នៅក្នុងសំណុំរឿងមួយផ្សេងទៀត ដូច្នេះហើយបានអនុញ្ញាតឲ្យពួកគាត់ធ្វើអន្តរាគមន៍ក្នុងនាមជាតតិយជន[27]។ ភាពជាក់ស្តែងដែលផ្តល់ឋានៈដល់អ្នកអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ គឺកម្រិតត្រឹមតែរឿងក្តីនេះទេ ដោយសារតែ*អ្នកមិនមែនជាភាគីនៃរឿងក្តី*ដើរតួនាទីយ៉ាងធំទូលាយដូចបានលើកឡើងខាងលើ នៅក្នុងការដាក់សារណាស្តីពីការទទួលរងផលប៉ះពាល់ដល់ផលប្រយោជន៍។

[27] សំណើនៃសំណុំរឿង ០០៣ កថាខណ្ឌ ៣ ដែលយោងទៅ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Kallon និង Kamara* សំណុំរឿងលេខ SCSL-2004-15-AR72(e) សេចក្តីសម្រេចលើការជំទាស់តវ៉ាទៅនឹងយុត្តាធិការ៖ ការអនុគ្រោះទោសដល់ Lomé Accord អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤។

១១. ទោះបីជាយ៉ាងក្តី អង្គជំនុំជម្រះតុលាការកំពូល ពិចារណាទៅលើឧទាហរណ៍នៃរឿងក្តី *Kallon និង Kamara*, បើទោះបីជារឿងក្តីនេះដាច់ដោយឡែកពីគេក៏ដោយ, ក្នុងការបង្ហាញពីភាពខុសប្លែកគ្នាយ៉ាងជាក់ច្បាស់រវាង*អ្នកមិនមែនជាភាគីនៃរឿងក្តី* និងអ្នកចូលធ្វើអន្តរាគមន៍, ពោលគឺ *អ្នកមិនមែនជាភាគីនៃរឿងក្តី* គឺបុគ្គល ឬជាស្ថាប័នដែលចាំបាច់ ដោយពុំទទួលបានផលប្រយោជន៍នៅក្នុងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី ចំណែកឯអ្នកចូលធ្វើអន្តរាគមន៍ គឺជាអ្នកដែលទទួលបានផលប្រយោជន៍ ហេតុនេះបានដើរតួនាទីស្មើរតែដូចភាគីនៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះហើយបទដ្ឋានផ្សេងគ្នាគប្បីត្រូវយកអនុវត្តចំពោះអ្នកដែលស្នើសុំតាំងខ្លួន*អ្នកមិនមែនជាភាគីនៃរឿងក្តី* និងអ្នកដែលស្នើសុំធ្វើអន្តរាគមន៍។ ជាពិសេស បញ្ហាដែលត្រូវពិចារណាជាបឋមក្នុងការទទួលឋានៈជា*អ្នកមិនមែនជាភាគីនៃរឿងក្តី* គឺថាតើ តុលាការ នឹងទទួលបានផលប្រយោជន៍នៅក្នុងការវិនិច្ឆ័យរឿងក្តីនេះ ដែរ ឬយ៉ាងណា។ ផ្ទុយទៅវិញ បញ្ហាដែលត្រូវពិចារណាជាបឋមក្នុងការអនុញ្ញាតឱ្យធ្វើបទអន្តរគមន៍ គឺថាតើ បទអន្តរាគមន៍នេះ គឺជាផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័នដែលស្នើសុំនោះ ហើយ បើត្រូវបានបដិសេធវិញនោះ ថាតើអាចរងផលប៉ះពាល់ ដែរ ឬយ៉ាងណា។

១២. ផលប្រយោជន៍របស់ជនសង្ស័យក្នុងសំណុំរឿង ០០៣ និង ០០៤ ចំពោះលទ្ធផលនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ស្របគ្នាទៅនឹងផលប្រយោជន៍របស់ នួន ជា និង ខៀវ សំផន។ ទោះបីជាយ៉ាងណាក៏ដោយ ទោះបីជាអន្តរាគមន៍អាចត្រូវបានអនុញ្ញាតក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាគីពុំមានកាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ដើម្បីឱ្យតុលាការស្តាប់បញ្ហាផ្លូវច្បាប់ ដែលអាចប៉ះពាល់ដល់ខ្លួនឡើយ[28]។ ការអនុវត្តបែបនេះ ត្រូវបានអនុញ្ញាត ប្រសិនបើកើតមាន ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។

[28] *សូមមើល ជាឧទាហរណ៍*...សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់ អៀង សារី សុំដាក់សារណាស្តីពីការអនុវត្តបាននៃទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយប្រឆាំងនឹងកាំង ហ្គេកអ៊ាវ *ហៅ* "ឌុច", ឯកសារលេខ D99/3/19, ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១៤ ("វាជាកត្តាមូលដ្ឋានសម្រាប់តុលាការ នៅពេលដែលកិច្ចដំណើរការនីតិវិធីមួយចំនួនពុំទាន់បានបញ្ចប់ សេចក្តីសម្រេចនៅក្នុងសំណុំរឿងមួយលើបញ្ហាផ្លូវច្បាប់ នឹងបំភ្លឺផ្លូវដល់តុលាការនៅក្នុងរឿងក្តីប្រហាក់ប្រហែលគ្នានាពេលអនាគត" ទោះបីជាយ៉ាងណាក្តី"វាពុំកើតចេញពីស្ថានភាពដែលថា ជនត្រូវចោទ មានសិទ្ធិធ្វើអន្តរគមន៍នៅក្នុងសំណុំរឿង ដែលខ្លួនពុំមែនជាភាគីក្នុងការដាក់ទស្សនៈរបស់ខ្លួនស្តីពីបញ្ហាណាមួយឡើយ")។

១៣. បញ្ហានៃការអនុវត្តន៍នូវគំនិតស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានលើកឡើងជាច្រើនដងនៅក្នុងសំណុំរឿង ០០១ និង ០០២។ ក្នុងរឿងក្តីបច្ចុប្បន្ន ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ បានដាក់សារណាជាលាយលក្ខណ៍អក្សរជាច្រើនទំព័រនៅចំពោះមុខអង្គបុរេជំនុំជម្រះ ជំទាស់ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលសម្រេចថា សហឧក្រិដ្ឋកម្មរួមអាចយកមកអនុវត្តបានទាំងបីទម្រង់ នៅចំពោះមុខ អ.វ.ត.ក[29] ដែលអង្គបុរេជំនុំជម្រះ បានបដិសេធផ្នែកខ្លះ ដោយសម្រេចថា សហឧក្រិដ្ឋកម្មទម្រង់ទី III មិនមែនជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិនៅក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ[30]។ ក្រោយមក នួន ជា ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ បានដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែមទៀតអំពីបញ្ហានេះ នៅពេលសវនាការ ដោយជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ទៅក្នុងសំណុំរឿង ០០២[31] សំណើនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធចោល ដោយមួយផ្នែក ផ្អែកទៅលើការវិភាគ

---

[29] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ឯកសារ D97/13 ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការដាក់ឲ្យអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា "សហឧក្រិដ្ឋកម្មរួម" ឯកសារ D97/16/1 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ (សម្ងាត់)។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់ថាជា "សហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D97/15/1 ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ឯកសារ D97/14/5 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០។

[30] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ឯកសារ D97/15/9 ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០។

[31] សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសមួយផ្សេងទៀត ឯកសារ E100/5 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ឯកសារ E100/3 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់ ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E100/2 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត ឯកសារ E100/1 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

របស់អង្គបុរេជំនុំជម្រះ[32]។ ដោយហេតុថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បង្កើតបានជាកម្មវត្ថុនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូល មានកាតព្វកិច្ចត្រូវពិចារណាលើសារណាពាក់ព័ន្ធទាំងអស់នៅក្នុងសំណុំរឿង បន្ថែមទៅនឹង សារណាទាំងឡាយដែលបានធ្វើឡើងជាមួយនឹងបណ្តឹងសាទុក្ខ។

១៨. ដោយពិចារណាទៅលក្ខណៈស្រប និងត្រួតគ្នានៃផលប្រយោជន៍ដែលបានស្នើឡើង និងវិសាលភាពដែលប្រធានបទនៃរឿងក្តីនេះ ត្រូវបានជំទាស់តវ៉ារួចហើយនោះ វាប្រាកដណាស់ថា ខ្លឹមសារនៃបទអន្តរាគមន៍ដែលបានស្នើឡើង អាចនឹងមានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងខ្លឹមសារទាំងឡាយដែលបានផ្តល់ឲ្យរួចហើយកាលពីពេលមុន ហើយនៅពេលនេះ នួន ជា និង ខៀវ សំផន បានបញ្ជាក់សាជាថ្មីនៅក្នុងសារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខ[33]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់បន្ថែមទៀតថា សហមេធាវីទាំងអស់ ដែលត្រូវបានចាត់តាំងជាមេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤ ធ្លាប់ជាសមាជិកនៃមេធាវីការពារក្តីលោក អៀង សារី។ ដោយសារតែលក្ខណៈដដែលលើបញ្ហាថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ ឬយ៉ាងណានោះ មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ និង ០០៤ ទំនងជាពុំអាចផ្តល់នូវកាលៈទេសៈ ឬទឡ្ហីករណ៍ថ្មីៗ ក្រៅតែពីកាលៈទេសៈ និងទឡ្ហីករណ៍ទាំងឡាយដែលបានដាក់រួចហើយ ក្នុងនាម អៀង សារី ដើម្បីបំភ្លឺបន្ថែមទៀតទៅលើបញ្ហានេះ។ សេចក្តីសន្និដ្ឋាននេះ ត្រូវបានគាំទ្រដោយការពិនិត្យឡើងវិញលើខ្លឹមសារនៃសារណារបស់*អ្នកមិនមែនជាភាគីនៃរឿងក្តី* ដែលមានឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងសំណើសុំក្នុងសំណុំរឿង ០០៣ និង ០០៤[34] ដែលមានលក្ខណៈច្រំដែលដូចគ្នានឹងសារណាពីមុនៗ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយពិចារណាទៅលើសារណាយ៉ាងច្រើន

---

[32] សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ឯកសារ E100/6 ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២៩។

[33] ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឯកសារ F11/1 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥។ សារណាតបរបស់ នួន ជា ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ F11/2 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥។

[34] ឧបសម្ព័ន្ធ ក សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីសហឧក្រិដ្ឋកម្មរួម ឯកសារលេខ F19.2, ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥ ។ សំណើរបស់មេធាវីការពារក្តីនៃសំណុំរឿង ០០៣ សុំធ្វើអន្តរាគមន៍ ឬ សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ ៣ ឯកសារលេខ F20.2 ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥។

លើសលប់នៅក្នុងសំណុំរឿង ផលប្រយោជន៍របស់មេធាវីការពារក្ដីក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានការពារយ៉ាងច្រើនរួចហើយ ដូច្នេះ ធ្វើឱ្យសំណាងដែលមេធាវីបានស្នើសុំនោះ មានលក្ខណៈលើសលប់ហួសពីភាពចាំបាច់។

## ឃ. ផ្នែកសម្រេចសេចក្ដី

១៥. យោងទៅលើសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**បដិសេធ** សំណើពីសំណុំរឿង ០០៣ និង ០០៤ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**